**AIA (Cambodia) Life Insurance Plc**

GIA Tower, 31st Floor, Sopheak Mongkul Street,
Phum 14, Sangkat Tonle Bassac, Khan Chamkar
Morn, Phnom Penh, the Kingdom of Cambodia

Tel: (855) 86 999 242

AIA.COM.KH

## Media Release

# **អេ អាយ អេ ខេមបូឌា រកឃើញម្ចាស់ពានរង្វាន់** AIA Corporate Cup 2025

*ក្រុមបាល់ទាត់របស់សាលាអន្តរជាតិ CIA First យកឈ្នះក្រុមចំនួន 28 ដើម្បីតំណាងកម្ពុជាឆ្ពោះទៅទីក្រុងឡុងដ៍ ចូលរួមប្រកួតបន្តនៅកីឡដ្ឋានរបស់ក្លឹបបាល់ទាត់ Tottenham Hotspur*

ភ្នំពេញទី 26 មករា 2025៖ អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ថ្ងៃនេះបាន បំពាក់មេដាយមាស និងពានរង្វាន់ម្ចាស់ជើងឯក AIA Corporate Cup 2025 ដល់ក្រុមបាល់ទាត់សាលាអន្តរជាតិ CIA First។ បន្ថែមពីលើជ័យលាភី មេដាយមាស និងពានរង្វាន់ដែលបង្ហាញថាជាក្រុមបាល់ទាត់ជើងខ្លាំងជាងគេក្នុងចំណោមក្រុមហ៊ុនសាជីវកម្ម ដែលជាអតិថិជនរបស់ អេ អាយ អេ ខេមបូឌា ក្រុមជើងឯកក៏ទទួលបានរង្វាន់ដំណើរកម្សាន្តទៅកាន់ទីក្រុងឡុងដ៍ជាមួយបទពិសោធដែលមិនអាចកាត់ថ្លៃបានផងដែរ។

រង្វាន់ដែលមិនអាចកាត់ថ្លៃបាននោះ រួមមានឱកាសប្រកួតតំណាងកម្ពុជានៅកីឡដ្ឋាន Tottenham Hotspur ក្នុងទីក្រុងឡុងដ៍ ដែលជាក្លឹបល្បីមួយរបស់ក្របខណ្ឌបាល់ទាត់ English Premier League ដើម្បីប្រកួតប្រជែងក្នុងពានរង្វាន់ AIA Championship 2025 ជាមួយក្រុមតំណាង អេ អាយ អេ មកពីបណ្ដាប្រទេសផ្សេងៗ។ ក្នុងអំឡុងពេលស្នាក់នៅទីនោះ ក្រុមម្ចាស់ជើងឯក AIA Corporate Cup ឆ្នាំនេះ ក៏ត្រូវបានអញ្ជើញទៅទស្សនាការប្រកួតក្នុងទឹកដីរបស់ក្លឹប Tottenham Hotspur  ផងដែរ។ រង្វាន់ដែលជាបទពិសោធមិនអាចកាត់ថ្លៃបាននេះ កើតចេញពីភាពដៃគូជាសកលរវាង អេ អាយ អេ គ្រុប (AIA Group) ជាមួយក្លឹបបាល់ទាត់ Tottenham Hotspur។

ក្រុមបាល់ទាត់ CIA First នឹងតំណាងឱ្យប្រទេសកម្ពុជាប្រកួតនឹងក្រុមម្ចាស់ជើងឯកតំណាង អេ អាយ អេ មកពីបណ្ដាប្រទេសផ្សេងទៀត ដែលការប្រកួតនឹងប្រព្រឹត្តឡើងនៅកីឡដ្ឋាន Tottenham Hotspur ថ្ងៃទី 11 ខែឧសភា ឆ្នាំ 2025។

មុនក្លាយជាជើងឯក គេឃើញថាក្រុម CIA First បានប្រកួតប្រជែងយ៉ាងស្វិតស្វាញជាមួយនឹងក្រុមបាល់ទាត់តំណាងស្ថាប័នចំនួន 28 ផ្សេងទៀត ចាប់ពីថ្ងៃទី 08 ខែធ្នូ ឆ្នាំ 2024 ដល់ថ្ងៃទី 26 ខែមករា ឆ្នាំ 2025។ ស្ថាប័នធំៗមួយចំនួនដែលបានចូលរួមប្រកួតប្រជែងដណ្ដើមពានរង្វាន់ឆ្នាំនេះមានដូចជា និយតករធានារ៉ាប់រងកម្ពុជា ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ធនាគារ ព្រីនស៍ សាលាអន្តរជាតិភ្នំពេញ (ISPP), foodpanda, KPMG, RMA Cambodia និង ផ្សារ MAKRO ។

នេះជារដូវកាលទី 2 នៃពានរង្វាន់ AIA Corporate Cup 2025 ដែលរៀបចំឡើងផ្តោតលើការគាំទ្រ និងលើកកម្ពស់សុខភាព និងសុខភាពរបស់អតិថិជនសាជីវកម្មរបស់ អេ អាយ អេ ខេមបូឌា ដែលជាក្រុមហ៊ុន

[AIA - INTERNAL]

**AIA (Cambodia) Life Insurance Plc**

GIA Tower, 31st Floor, Sopheak Mongkul Street,
Phum 14, Sangkat Tonle Bassac, Khan Chamkar
Morn, Phnom Penh, the Kingdom of Cambodia

Tel: (855) 86 999 242

AIA.COM.KH

## Media Release

ជានាវ៉ាប់រងអាយុជីវិត និងសុខភាពឈានមុខគេមួយ។ ការប្រកួតដណ្តើមពានរង្វាន់នេះ ក៏អាចឱ្យអតិថិជនរបស់ខ្លួនបង្កើនការភ្ជាប់ទំនាក់ទំនងកាន់តែប្រសើរ និងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក ហើយក៏ជាផ្សារភ្ជាប់ជីវិតរស់នៅជាមួយកីឡាដើម្បីជីវិតដ៏សកម្មដែលជាគ្រឹះទទួលបានសុខភាពល្អ។

ក្នុងនាមជាក្រុមហ៊ុនឈានមុខគេលើអត្ថប្រយោជន៍និយោជិត ពានរង្វាន់បាល់ទាត់នេះ ក៏ជាផ្នែកមួយនៃកម្មវិធី WorkWell with AIA ដែលមានគោលបំណងពង្រឹង សុខុមាលភាពដល់អតិថិជនសាជីវកម្មរបស់ខ្លួនជាមួយការប្តេជ្ញាចិត្តធ្វើជាដៃគូជាទីទុកចិត្តក្នុងការជួយនិយោជក និងនិយោជិតនៅកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងជីវិតកាន់តែប្រសើរ។

កម្មវិធី WorkWell with AIA មានសសរស្តម្ភបួនដែលបានបង្កើតឡើងជាពិសេសដើម្បីជានានូវសុខុមាលភាពពេញលេញរបស់និយោជិត ដែលរួមមាន៖ សុខមាលភាពរាងកាយ សុខមាលភាពផ្លូវចិត្ត សង្គម និងហិរញ្ញវត្ថុ។

ពានរង្វាន់នេះទៀតសោធ គាំទ្រដល់គោលបំណងរបស់ អេ អាយ អេ ខេមបូឌា ដែលស្របតាមគំនិតផ្តួចផ្តើម AIA One Billion របស់ អេ អាយ អេ គ្រុប (AIA Group) ដើម្បីជួយប្រជាជនមួយពាន់លាននាក់នៅអាស៊ីរួមទាំងកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ នៅឆ្នាំ 2030។ ពានរង្វាន់ AIA Corporate Cup ក៏ទទួលបានការគាំទ្រ និងរៀបចំការប្រកួតដោយក្លឹប អាយ អេស អាយ ដង្កោសែនជ័យ ដែលជាក្លឹបបាល់ទាត់របស់ខេមបូឌានព្រីមៀរលីគ។

ក្នុងព្រឹត្តិការណ៍ប្រកួតផ្តាច់ព្រ័ត្រនេះ លោកស្រី Jane Tay អគ្គនាយិកាក្រុមហ៊ុន អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា៖ “នាងខ្ញុំសូមអបអរសាទរដល់ក្រុមបាល់ទាត់សាលាអន្តរជាតិ CIA First ដែលបានបញ្ចេញទេពកោសល្យបាល់ទាត់ដោយរក្សាបាននូវស្មារតីកីឡា ការសហការជាក្រុម ចេះអធ្យាស្រ័យគ្នា ដែលជាភាពស្រស់ស្អាតនៃបាល់ទាត់ និងជាគំរូគួរឱ្យគោរព។ ខ្ញុំក៏សូមអបអរសាទរដល់បណ្តាក្រុមដទៃទៀត និងអ្នកដែលបានចូលរួមទាំងអស់ចំពោះការខិតខំប្រឹងប្រែងនិងពេលវេលារបស់ពួកគាត់ក្នុងការរៀបចំឱ្យពានរង្វាន់ AIA Corporate Cup ទទួលបានជោគជ័យ ដែលជាបទពិសោធមួយមិនអាចបំភ្លេចបាន។

“អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាព ឈានមុខគេលើអត្ថប្រយោជន៍បុគ្គលិក ហើយ AIA Corporate Cup គឺជាកម្មវិធីមួយដែលមានតែយើងប៉ុណ្ណោះ អាចផ្តល់ជូនបានដើម្បីជាប្រយោជន៍ដល់សុខមាលភាព និងការភ្ជាប់ទំនាក់ទំនងដល់និយោជក និងនិយោជិត។ អេ អាយ អេ ខេមបូឌា ក៏ជាអ្នកគាំទ្រយ៉ាងសកម្មលើគ្រប់ប្រភេទកីឡា ជាពិសេសបាល់ទាត់ដែលផ្តល់នូវអត្ថប្រយោជន៍ផ្លូវចិត្ត និងផ្លូវកាយជាច្រើនដើម្បីជំរុញ និងជួយឱ្យប្រជាជនកម្ពុជារស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ”។

**AIA (Cambodia) Life Insurance Plc**

GIA Tower, 31st Floor, Sopheak Mongkul Street, Phum 14, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, the Kingdom of Cambodia

Tel: (855) 86 999 242

AIA.COM.KH

## Media Release

តើក្រុមបាល់ទាត់ CIA First នឹងទទួលបានលទ្ធផលយ៉ាងណាពេលប៉ះក្រុមបាល់ទាត់មកពីបណ្តា អេ អាយ អេ តាមប្រទេសផ្សេងទៀតក្នុងព្រឹត្តិការណ៍ AIA Corporate Cup 2025 នៅទីក្រុងឡុងដ៍? ដើម្បីតាមដានលទ្ធផលរបស់ពួកគាត់ និងទទួលបានព័ត៌មានថ្មីៗ សូមតាមដានលើទំព័រហ្វេសប៊ុក facebook.com/AIACambodia ឬជាចូលជាសមាជិក Wellness@Work តាមរយ: https://www.facebook.com/share/g/1ZoAPXEXfw/

ព័ត៌មានបន្ថែមអំពីកម្មវិធីសុខភាព និងសុខុមាលភាពរបស់ អេ អាយ អេ ខេមបូឌា សូមចូលទៅ aia.com.kh ឬ facebook.com/AIACambodia ។

ព័ត៌មានលម្អិតលើការទទួលយកដំណោះស្រាយការការពារលោកអ្នក និងគ្រួសារពី អេ អាយ អេ ខេមបូឌា លើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ និងការធានារ៉ាប់រងសុខភាពជាក្រុម សូមទាក់ទង AIA Client Care តាមរយ:លេខ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh។

**អំពី អេ អាយ អេ ខេមបូឌា ៖**

*ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*

*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជាផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជា ផ្តល់ដំណោះស្រាយការពារលើជំងឺធ្ងន់ធ្ងររហូតដល់ 118 ករណីដំបូងគេនៅកម្ពុជាចាប់ពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយ។*

*ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា  អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំ*

**AIA (Cambodia) Life Insurance Plc**

GIA Tower, 31st Floor, Sopheak Mongkul Street,
Phum 14, Sangkat Tonle Bassac, Khan Chamkar
Morn, Phnom Penh, the Kingdom of Cambodia

Tel: (855) 86 999 242

AIA.COM.KH

## Media Release

*ខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*

*អេ អាយ អេ ខេមបូឌា ផ្ដោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្ដួចផ្ដើម រួមមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។*

*យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លិបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លិបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*

*អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ “ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)” ពី HR Asia ក្នុងរយៈពេល 4ឆ្នាំជាប់គ្នាពី 2020 ដល់ 2023។ អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្ដាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*

Media Contact
Ren Pisal
Corporate Communications Manager
Pisal-P.ren@aia.com

[AIA - INTERNAL]